គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស

**COMMITTEE FOR ELECTION RIGHTS OF OVERSEAS CAMBODIANS (THE CEROC)**

**Email:** board@khmeroversea.info, www.khmeroversea.info

# ជំរាបជូនឯកឧត្តម សិក ប៊ុនហុក ប្រធាន គ.ជ.ប

**កម្មវត្ថុ៖** គួរពិចារណាទៅលើធម្មនុញ្ញភាពនៃគណកម្មការជាតិរៀបចំការបោះឆ្នោត គួរឬមិនគួរបន្តរៀបចំការបោះឆ្នោតជាតិថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ។

គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសហៅកាត់ថាស៊ីរ៉ក់ ដែលរមែងទាមទារសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសកុំអោយមានការរើសអើង រមែងឃ្លាំមើលដំណើរការបោះឆ្នោតដោយសុក្រឹតយុត្តិធម៌ និងជាអ្នកជំនាញក្នុងយន្តការបោះឆ្នោតដែលអាចធានាបាននូវតំលៃនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ថ្មីៗនេះ យើងខ្ញុំមានការខកចិត្តជាខ្លាំងចំពោះវិធានការរបស់លោកនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងពត៌មានក្នុងការចាប់លោកកឹម សុខា ជាប្រធានគណបក្សជំទាស់ធំជាងគេបំផុតក្នុងប្រទេសកម្ពុជានិងការបិទស្ថានីយ៍វិទ្យុដែលផ្សាយពត៌មានឯករាជ្យចំនួន១៩ស្ថានីយ៍។ ហេតុការណ៍ចុងក្រោយនេះគឺជាការគំរាមកំហែងជាក់ស្តែងមួយដល់ការបំពេញការងារប្រកបដោយវិជ្ជាជីវៈរបស់គ.ជ.ប ក្នុងនាមជាស្ថាប័នឯករាជ្យមួយស្ថិតក្រោមរដ្ឋធម្មនុញ្ញតែម្យ៉ាងដូចគ្នានឹងស្ថាប័នព្រះមហាក្សត្រផងដែរ។ ម្យ៉ាងវិញទៀតសោតសហគមអន្តរជាតិកំពុងមើលឃើញថារដ្ឋាភិបាលបច្ចុប្បន្នគឺអសមត្ថភាពក្នុងការរក្សារបបប្រជាធិបតេយ្យសេរីពហុបក្សទៅតាមរដ្ឋធម្មនុញ្ញខ្មែរដែលមានជាធរមានជាពិសេសគឺគាំទ្រពេញទំហឹងដល់អង្គភាពគ.ជ.ប ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមច្បាប់បោះឆ្នោតដែលមានជាធរមាន។

ហេតុដូច្នោះ សូមសមាជិកទាំង៩រូបតាមមាត្រា៤ គួរប្រើបុព្វសិទ្ធិរបស់ខ្លួនតាមមាត្រា៨ ដើម្បីសិក្សាអោយបានគ្រប់ជ្រុងជ្រោយនូវលទ្ធភាពរបស់ខ្លួនក្រោមបរិយាកាសនយោបាយបច្ចុប្បន្នថាតើគួរត្រូវធ្វើដូចម្តេច? - គួរសួរទៅរាជរដ្ឋាភិបាលអោយបានជាក់ច្បាស់ថាតើអាចធានាអោយគ.ជ.បដំណើរកិច្ចការរបស់ខ្លួនតទៅមុខទៀតឬត្រូវបញ្ឈប់ ពីព្រោះរាជរដ្ឋាភិបាលហាក់កំពុងប្រកៀកស្មាជាមួយចិនដែលស្ទីលនៃការបោះឆ្នោតគឺខុសពីកម្ពុជាដូចមេឃនិងដី? - គួរសិក្សាទៅលើអធម្មនុញ្ញភាពនៃគ.ជ.ប ប្រសិនបើរាជរដ្ឋាភិបាលអាចចាប់ដាក់គុកឬកំចាត់ទៅលើដៃគូរប្រកួតប្រជែងតែមួយគត់របស់ខ្លួនក្នុងឋានៈខ្លួនជាគណបក្សដឹកនាំរាជរដ្ឋាភិបាល បានគ្រប់ពេលវេលាដូចសព្វថ្ងៃនេះ?

*សូមឯកឧត្តមទទួលបាននូវពុទ្ធពរទាំងឡាយ៤ប្រការកុំបីឃ្លៀងឃ្លាតឡើយ។*

ធ្វើនៅប្រទេសកាណាដា ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៧

**សេង សុភ័ណ**

ប្រធានគណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស

Committee for Election Rights of Overseas Cambodians (The CEROC)
Contact: 6596 Marlborough Ave., Burnaby, BC, V5H 3M1, Canada
Tel: 604-428-4385, Fax: 604-620-3433